ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៤៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលមាត្រា១៦ នៃអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា

~~~~~~~~~

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងសេវា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
~~~~~~~~~

- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការត្រួតពិនិត្យភូតគាមអនាម័យ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា មួយ.-**

មាត្រា១៦ នៃអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានកែសម្រួល ដូចខាងក្រោម ៖

**មាត្រា ១៦ថ្មី.-**

.ផ្នែកទី១ ៖

ក្រុមត្រួតពិនិត្យនៅស្ថានីយអ្នកដំណើរអន្តរជាតិ មានសមាសភាព ៖

- មន្ត្រីនគរបាលជាតិ នៃនាយកដ្ឋានអន្តោប្រវេសន៍ អគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ ប្រធាន
- មន្ត្រីគយ និងរដ្ឋាករនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- មន្ត្រីកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម សមាជិក
- មន្ត្រីត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ នៃក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ សមាជិក
- មន្ត្រីភូតគាមអនាម័យ នៃក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ សមាជិក
- កម្លាំងសន្តិសុខ នៃក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ សមាជិក

• ផ្នែកទី២ :

ក្រុមត្រួតពិនិត្យនៅមណ្ឌលឃ្លាំងទំនិញ មានសមាសភាព :

- មន្ត្រីគយ និងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធាន
- មន្ត្រីនគរបាលជាតិ នៃនាយកដ្ឋានអន្តោប្រវេសន៍ អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ សមាជិក
- មន្ត្រីកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម សមាជិក
- មន្ត្រីត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ នៃក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ សមាជិក
- មន្ត្រីភូតគាមអនាម័យ នៃក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ សមាជិក
- កម្លាំងសន្តិសុខ នៃក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ សមាជិក

ចំនួនសហការីនៃក្រុមត្រួតពិនិត្យ នៅស្ថានីយអ្នកដំណើរអន្តរជាតិ និងមណ្ឌលឃ្លាំងទំនិញ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ដោយមានការឯកភាពពីក្រសួង ស្ថាប័ន សាមីនីមួយៗ ។

## មាត្រា ៣ :

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

## មាត្រា ៤ :

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន និងអភិបាលខេត្ត ក្រុងពាក់ព័ន្ធ និងក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៦

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សុខ អាន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៤
-ឯកសារ កាលប្បវត្តិ